រាជធានីភ្នំពេញ , ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ១៩៩៤

# សេចក្ដីសំរេចលេខ ០០៤ សសរ.សហវ ស្ដីពីការបង្កើតគណៈកម្មការ ដោះស្រាយពាក្យបណ្ដឹងតវ៉ារបស់ម្ចាស់យានយន្តពេលមានបង្កាន់ ដៃពន្ធគយក្លែងក្លាយតែមានប័ណ្ណសំគាល់យានយន្តត្រឹមត្រូវ កាត់ឈ្មោះបាន

* * * *

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ វរ្ម័ន ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្ដីពីពន្ធលើទំនិញនាំចេញ និង នាំចូលដែលប្រកាសអោយប្រើដោយក្រឹត្យលេខ ៥៧ ក្រ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៨៩
- បានឃើញលិខិតលេខ ១៨៧ សជណ.ពហ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ១៩៩៣ របស់ទីស្ដីការគណៈរដ្ឋមន្ត្រី ស្ដីពីវិធានការកែលំអប្រព័ន្ធគយ និង រដ្ឋាករ
- បានឃើញសេចក្ដីជូនដំណឹងលេខ ០១៧ សហវ.សជណ ចុះថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្ដីពីការលក់លតាប័ត្រសំរាប់រថយន្តដែលកំពុងចរាចរក្នុងប្រទេសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញការងារចាំបាច់របស់ក្រសួង

## សំរេច

ប្រការ ១ : បង្កើតគណៈកម្មការ ដោះស្រាយពាក្យបណ្ដឹងតវ៉ា របស់ម្ចាស់យានយន្តពាក់ព័ន្ធនិងបង្កាន់ដៃពន្ធគយក្លែងក្លាយដែលមានប័ណ្ណសំគាល់យានយន្តត្រឹមត្រូវកាត់ឈ្មោះបាន ដែលមានសមាសភាពដូចខាងក្រោម ÷

| | |
|---|---|
| ១ - ឯកឧត្ដម ទេសរដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | ប្រធាន |
| ២ - មន្ត្រីគយពីររូប | សមាជិក |
| ៣ - មន្ត្រីអធិការកិច្ចពីររូប | សមាជិក |

៤ - មន្ត្រីពីររូបជាតំណាងក្រសួងសាធារណការ និង ដឹកជញ្ជូន — សមាជិក

៥ - មន្ត្រីពីររូបជាតំណាងក្រសួងយុត្តិធម៌ — សមាជិក

៦ - តំណាងម្ចាស់យានយន្តពីររូប — សមាជិក

ប្រការ ២ : គណៈកម្មការនេះ មានភារកិច្ចដោះស្រាយរាល់ពាក្យបណ្តឹងផ្សេងៗ នៃម្ចាស់យានយន្តដែលពាក់ព័ន្ធទៅនឹងបង្កាន់ដៃពន្ធគយក្លែងក្លាយ ហើយមានប័ណ្ណសំគាល់យានយន្តដែលចេញដោយក្រសួងសាធារណការ និង ដឹកជញ្ជូន ដើម្បីស្វែងរកការពិត និង ផ្តល់យុត្តិធម៌ជូនម្ចាស់យានយន្តដែលត្រូវគេបំភ័ន្ត ។

ប្រការ ៣ : គណៈកម្មការនឹងស្នើសុំទៅរាជរដ្ឋាភិបាល ដើម្បីចាត់វិធានការសមស្របចំពោះមន្ត្រីរាជការទាំងឡាយណាដែលបានរួមចំណែកក្នុងការប្រព្រឹត្តអំពើក្លែងបន្លំ និង រំលោភច្បាប់ ។

ប្រការ ៤ : លោកប្រធានមន្ទីរ ប្រធាននាយកដ្ឋានចំណុះក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង សាមីខ្លួន ខាងលើត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ ៕

ទេសរដ្ឋមន្ត្រី

និង ជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ហត្ថលេខា និង ត្រា

សម រង្ស៊ី

* * * *

## ២ - ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ១៩៩៤

## ប្រកាសលេខ ០១១ ប្រ.សហវ ស្តីពីការបែងចែកឥណទានផ្ទេរក្នុងជំពូកតាមប្រការ កថាខ័ណ្ឌ នាក្យខ័ណ្ឌ ជូនបណ្តាក្រសួង តាមឥណទានចែងក្នុងច្បាប់ហិរញ្ញវត្ថុ សំរាប់ឆ្នាំ ១៩៩៤

* * *